00277281

**Declassified to Public**
**06 September 2012**

E2/5/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតជូនដំណឹង

នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា អត្តលេខ ៨៤៥ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការិយាល័យមានអាសយដ្ឋានផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ORIGINAL DOCUMENT RECEIVED ON 23-01-2009
AT: 11:30
BY SANN RADA
COURT OFFICER

សូមមេត្តាជ្រាប ។

**កម្មវត្ថុ:** សូមជូនដំណឹងស្តីពីមរណភាពរបស់កូនក្តីនាងខ្ញុំឈ្មោះ **សួស សារិន** ភេទស្រី អាយុ៥២ឆ្នាំ កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៨ ដោយរោគាពាធ និងសូមទទួលស្គាល់ លោក **អ៊ុម ពិសិដ្ឋ** អាយុ៥៩ឆ្នាំ មានទីលំនៅ ភូមិទួលអង្គប់ ឃុំសំបួរ ស្រុកស្វាយទាប ខេត្តស្វាយរៀង (ត្រូវជាប្តីរបស់សព) ធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំនួស ក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**យោង:**
- សំណុំរឿងលេខ០០១/១៨-០៧-២០០៧របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- លិខិតជូនដំណឹងពីការទទួលស្គាល់ជា ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៦-០៨-២០០៨
- សំបុត្រមរណភាព ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩
- សំណើរសុំតែងតាំងអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ច្បាប់ដើម ១ច្បាប់)
- សៀវភៅគ្រួសារលេខ គ០២៦២៩ ចុះឆ្នាំ២០០០ របស់ឈ្មោះ អ៊ុម ពិសិដ្ឋ

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជំរាបជូន **លោកប្រធានសាលាដំបូង** មេត្តាជ្រាបថា: កូនក្តីនាងខ្ញុំឈ្មោះ សួស សារិន បានទទួលមរណភាពកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៨ ដោយរោគាពាធ ។ ក៏ប៉ុន្តែ មុនពេលដែលកូនក្តីនាងខ្ញុំទទួលមរណភាព គាត់បានផ្តិតមេដៃប្រគល់សិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងសំណុំរឿងខាងលើរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទៅអោយប្តីគាត់ឈ្មោះ អ៊ុម ពិសិដ្ឋ ដើម្បីចូលរួមពាល់នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជំនួសគាត់ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **លោកប្រធានសាលាដំបូង** មេត្តាជ្រាបជា ពត៌មាន និងទទួលស្គាល់លោក អ៊ុម ពិសិដ្ឋ ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងខាងលើតាមច្បាប់ចាប់ពីថ្ងៃនេះតទៅ ។

សូមលោក **ប្រធានសាលាដំបូង** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ ២០០៩
ហត្ថលេខា

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

[signature]

**មេធាវី.ទី-ស្រ៊ីនណា**

| **ឯកសារដើម**<br>ORIGINAL DOCUMENT/DOCUMENT ORIGINAL | **ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**<br>CERTIFIED COPY/COPIE CERTIFIÉE CONFORME |
| --- | --- |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 01 / 2009 | ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 01 / 2009 |
| ម៉ោង (Time/Heure): 10:00 | |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature] | មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature] |